# ការសំភាសរបស់អ៊ំស្រី ថៃ គឹមស្រិន

ក៖ អ្នកសំភាសគេនិងមាន សួន សុខលី     ខ៖ អ្នកដែលត្រូវបានគេសំភាស ថៃ គឹមស្រិន

ក៖
ជាដំបូងខ្ញុំសូមថ្លែងអំណរគុណដស់អ៊ំស្រីដែលអោយខ្ញុំធ្វើការសំភាសជីវប្រវិត្តរបស់អ៊ំស្រី ហើយការសំភាសនេះគឺធ្វើឡើងដោយសារសកលវិទ្យាលយ័ BYU ដោយសារតែសកលវិទ្យាល័យនិងចង់ថែរក្សារប្រវិត្តជីដូនជីតារបស់អ៊ំស្រីទុក្ខអោយកូនចៅជំនាន់ក្រោយមើល ហើយនិងស្តាប់ ហើយបន្ទាប់ពីការសំភាសនេះរួចហើយ តើខ្ញុំអាចសុំដាក់ការសំភាសមនេះនៅក្នុងប្រពន្ធ័វីបផ្សាយមួយដែលមានឈ្មោះថា www. Cambodianoralhistories.byu.edu បានដែលទេអ៊ំស្រី? ។

ខ៖ ចានៅជំនាន់ពពតនិងយ៉ាប់ណាស់គ្រប់បែកទំលាក់។

ក៖ ចាហើយខ្ញុំជាអ្នកសំភាសមានឈ្មោះថា សួន សុខលី ហើយការសំភាសនេះធ្វើឡើងនៅថ្ងៃទី ៣១ ខែ០១ ឆ្នាំ២០១៨ ដែលមានទីតាំងនៅភូមិបូនអើសង្កាត់ផ្សារដើមថ្កូវ ខ័ណ្ឌចំការមន រាជធានីភ្នំពេញ។

ក៖ ចឹងខ្ញុំចង់សួរអ៊ំស្រីថាអ៊ំ មានឈ្មោះអី ហើយមាននាមត្រកូលអីដែលអ៊ំ?

ខ៖ ខ្ញុំឈ្មោះ ថៃ គឹមស្រិន។

ក៖ ចាហើយអើអ៊ំមានថ្ងៃខែឆ្នាំកំណើត នៅកន្លែង
អនៅថ្ងៃទីប៉ុន្មានខែណាឆ្នាំណាដែលអ៊ំ?

ខ៖ ខ្ញុំភ្លេចអស់ហើយ ហាហា។

ក៖ ហាហាអ៊ំអត់ចាំ តែអ៊ំអាចចាំឆ្នាំ?

ខ៖ ឆ្នាំក៏អត់ចាំដែល។

ក៖ ចាហើយចុះឆ្នាំខ្មែរអ៊ំកើតឆ្នាំអីអ៊ំ?

ខ៖ ឆ្នាំខ្មែរក៏អត់ចាំដែល។

ក៖ ចាដូចជាឆ្នាំ រការ ជូត ឆ្លូវអីណាអ៊ំ?

ខ៖ អរខ្ញុំឆ្នាំរការ។

ក៖ ចាចុះអំគិតថានៅឆ្នាំ មួយពាន់ប្រាំបួនរយប៉ែតប៉ុន្មាន ដូចជាហារប៉ុនន្មាន ហុកប៉ុនន្មាន?

ខ៖ មិនដឹងជាប៉ែតប៉ុន្មានអី ប៉ុន្មានទេនេះ អត់ចាំផងនិងខ្ញុំ អត់ចាំទេ។

ក៖ ហើយអំមានស្រុកកំណើតនៅណាដែលអំ?

ខ៖ នៅកំពង់ចាម ស្រុកត្បូងឃ្មុំ ។

ក៖ កំពង់ចាម ស្រុកត្បូងឃ្មុំ មានភូមិឃុំអីដែលអំ?

ខ៖ ស្រុកត្បូងឃ្មុំ ខេត្តកំពង់ចាម។

ក៖ ចាស្រុកត្បូងឃុំ ខេត្តកំពង់ចាម ហើយចុះអំមានឈ្មោះហៅក្រៅទេអំ?

ខ៖ ឈ្មោះហៅក្រៅអី?

ក៖ ចាដូចជាគេហៅ មីអូន ឬក៏ស្រីពៅអីចឹងណាអំ?

ខ៖ និងហើយឈ្មោះខ្ញុំហៅក្រៅឈ្មោះ ញ៉។

ក៖ ឈ្មោះ ញ៉។

ខ៖ និងហើយ។

ក៖ ចាគេហៅតាំងពីក្មេងមកអីអំ?

ខ៖ និងហើយ។

ក៖ ហាហាចា។ ហើយខ្ញុំចង់សួអំថាអាឡូវនិងអំមានអាយុប៉ុន្មានហើយ?

ខ៖ ដូចជាហុកប៉ុន្មានទេ ហុកពីរអី។

ក៖ ចាចឹងអំមានទីកនកលែងកំណើតរបស់អំនៅស្រុកកំពង់ចាម។

ខ៖ ស្រុកត្បូងឃ្មុំ។

ក៖ ស្រុកត្បូងឃ្មុំ ហើយចុះខ្ញុំចង់សួរអំទៀតថា អំមានបងប្អូនជំនួនប៉ុនន្មាននាក់ដែល?

ខ៖ ខ្ញុំមានបងប្អូនប្រាំនាក់។

កៈ ចាចុះអ៊ំកូនទីប៉ុន្នាន?

ខៈ ខ្ញុំកូនទីបីរ។

កៈ ទីបីរ។

កៈ
ចាចឹងខ្ញុំអាចសុំរំខាន់អ៊ំជួយរៀបរាប់ឈ្មោះពីកូនបងរហូតដល់ប្អូនណាថាគាត់មានឈ្មោះអី
?

ខៈ អើកូនបងមានឈ្មោះថា ជ្រា ទីពីរជ្រុន អានិងអ្នកដែលនៅរស់ទេណា។

កៈ ចាអ៊ំ។

ខៈ បានមកខ្ញុំ គឹមស្រិន និងណា ហើយមកបានឈ្មោះ ស្រ៊ុន
ហើយបានឈ្មោះស្រៀងប្រុស និងហើយ។

កៈ ចុះអ្នកស្លាប់ដែលអ៊ំមានឈ្មោះអី?

ខៈ អ្នកស្លាប់ឈ្មោះជ្រឹន ហើយនិង ស្រៀង។

កៈ ចាចឹងអ៊ំមានបងប្អូនស្លាប់ពីរនាក់នុះអ៊ំនុះ?

ខៈ ចាស្លាប់អស់ពីរនាក់ ស្លាប់នៅជំនាន់អាពពតម្នាក់។

កៈ ចាហើយមានប្រុសស្រីប៉ុន្នាននាក់ដែលទៅអ៊ំ?

ខៈ មើលស្រីបួន ប្រុសមើលប៉ុន្នាន ប្រុសនិយាយទាំងអ្នកងាប់អីមែន?

កៈ ចាអ៊ំ។

ខៈ មើលទាំងអស់មានប្រុសបីរ។

កៈ ចា ចឹងប្រុសពីរ ស្រីបីរ?

ខៈ អត់ទេប្រុសបីរ ស្រីបួន។

កៈ ចាចឹងបងប្អូនអ៊ំទាំងអស់ប្រាំបួននាក់ ប្រាំបួននាក់ទាំងងាប់?

ខៈ ចាប្រាំបួននាក់ទាំងងាប់។

កៈ ចាទាំងងាប់ចា។ ហើយអើខ្ញុំចង់សួរអ៊ំទៀតថា តើឪពុកម្ដាយរបស់អ៊ំគាត់អើ អរសំទោសអ៊ំ។

កៈ ខ្ញុំចង់សួរអ៊ំទៀតថាតើអ៊ំមានចង់ចាំសាច់រឿងអ្វីខ្លះពីឪពុកម្ដាយអ៊ំណា?

ខៈ ទាំងពីរពួកគាត់មកនេះ?

កៈ ចាអ៊ំកាលពីអ៊ំនៅក្មេងតាំងពីបងប្អូនអ៊ំអីមកណា?
ដូចជាធ្លាប់រត់លេងអីជាមួយគ្នាចឹងណា?

ខៈ ទេកាលនៅរត់លេងជាមួយគ្នានិងមានអីនៅឯស្រុកអីនោះ
កាលនិងខ្ញុំនៅតូចៗខ្ញុំមិនសូវដឹងអីទេណា និងហើយខ្ញុំមិនចាំអីទេ
រត់លេងតែជាមួយគ្នានិងប្អូនៗខ្ញុំនុះ រកស៊ីរកអីនិង។

កៈ ចាចុះអ៊ំនៅពីក្មេងណាតើអ៊ំអើចូលចិត្តធ្វើអីគេដែលអ៊ំ?

ខៈ អើនេះខ្ញុំចូលចិត្តមើលម៉ែខ្ញុំគាត់ធ្វើនំគ្រៀបណា នំគ្រៀបគេអាំងនុះ។

កៈ ចាអ៊ំ។

ខៈ និងហើយ។

កៈ ហើយអើ។

ខៈ កាលនិងខ្ញុំទៅជួយធ្វើគាត់ចឹងណា ជួយអាំងនំអោយគាត់។

កៈ ចាអ៊ំហើយឪពុកម្ដាយអ៊ំមានឈ្មោះអីគេដែលអ៊ំ?

ខៈ ឈ្មោះជ្រឺន ហើយនិង ឈ្មោះ ហ៊ាន។

កៈ ឈ្មោះជ្រឺន ហើយនិង ឈ្មោះហ៊ាន។ ម្ដាយឈ្មោះជ្រឺន ហើយនិងឪពុកឈ្មោះ ហ៊ាន?

ខៈ ចាម្ដាយឈ្មោះជ្រឺន និងឪពុកឈ្មោះហ៊ាន។

កៈ ចាចុះនាមត្រកូលរបស់ពួកគាត់វិញអ៊ុំ?

ខៈ ម្ដាយនួន ជ្រឺន។

កៈ នួនជ្រឺន ចុះឪពុកវិញ?

ខៈ ឪពុកឈ្មោះ ស្អីទេនេះ ដូចជាកើតហ៊ាន។

កៈ ឈ្មោះកើត ហ៊ាន ចាហើយគាត់កើតនៅឆ្នាំណាខែណាដែលអ៊ំ។

ខៈ ខ្ញុំអត់សូវដឹងដែល។

កៈ ចាហើយអាឡូវនិងអ៊ំពួកគាត់ស្លាប់អស់ហើយ ឬក៏នៅរស់?

ខៈ ស្លាប់អស់ហើយ។

កៈ ស្លាប់អស់ហើយ ពួកគាត់ស្លាប់នៅឆ្នាំណាដែលអ៊ំ?

ខៈ ទេអត់ចាំឆ្នាំទេ ស្លាប់កាលនិងអាពពតហ៊ៅ។

កៈ អរអាពពតហៅ មើលកាលនិងនិងដាច់អាពពតដូចជាចិតសិបប្រាំហើយនៃអ៊ំ
ចឹងបើដាច់អាពពតហើយចូលដូចជាចិតសិបប្រាំមួយ ចិតសិបប្រាំពីរអីចឹងណាអ៊ំ។

ខៈ និងហើយចា។

កៈ ហើយស្រុកកំណើតរបស់ពួកគាត់នៅកន្លែងណាដែលអ៊ំ?

ខៈ នៅកោះសំរុង។

កៈ នៅកោះសំរុង ខេត្តអីគេដែលអ៊ំ?

ខៈ នៅស្រុកក្រូចឆ្មារនិង ដូចជាខេត្តកំពុងចាមដែលទេដឹង កាលនិង។

កៈ អរចា។

ខៈ នៅកោះសំរុង កោះនេះនិង។

កៈ ចាហើយអ៊ំមានដឹងថាឆ្នាំខ្មែរពួកគាត់មានឆ្នាំអីគេដែល? ដូចជា ជូត កុល អីណាអ៊ំ?

ខៈ លឺថាដូចជាឆ្នាំអីគេទេនេះពួកគាត់និងណា ដូចជាមិនសូវដឹងដែលខ្ញុំ មិនដឹងដែល។

កៈ ចាហើយខ្ញុំសូមសួរអ៊ំទៀតថា តើឪពុករបស់អ៊ំណាគាត់
ប្រកបមុខរបបអ្វីខ្លះសំរាប់ចិញ្ចឹមជីវិតរបស់គាត់ណា?

ខៈ គាត់រកត្រី។

កៈ គាត់រកត្រី តែមួយមុខនិងទេអំ?

ខៈ ចានិងហើយ។

កៈ ចាហើយឪពុករបស់អំគាត់គឺជាមនុស្សបែបណាដែលសំរាប់អំ? ដូចជាល្អ ស្លូត?

ខៈ គាត់គឺជាមនុស្សល្អទេគាត់នោះ ហើយគាត់ស្លូត ស្លូតបូតនិងហើយ។

កៈ ចាហើយគាត់ធ្លាប់វៃអំទេ ហាហាហា?

ខៈ ដូចជាមិនដែលទេ។

កៈ ចាហើយចុះម្តាយរបស់អំវិញគាត់ប្រកបមុខរបបអីដែលសំរាប់ចិញ្ចឹមជីវិតណាអំ?

ខៈ គាត់គឺជាអ្នកលក់នំគ្រៀប គាត់ធ្វើនំគ្រៀបលក់។

កៈ ចាហើយគាត់ជាមនុស្សបែបណាដែលសំរាប់អំ?

ខៈ គាត់ស្លូតដែលទេ គាត់នេះមិនសូវកោងកាច់អីទេ។

កៈ ចាចុះគាត់ធ្លាប់ប្រាប់ពីរសាច់រឿងរបស់ពួកគាត់ប្រាប់អំអត់អំ?។

ខៈ ពួកគាត់អត់ដែលប្រាប់អីផង។

កៈ ចានៅពីរក្មេងអីអត់ដែលប្រាប់ដែលអំ?

ខៈ និងហើយចា អត់ដែលប្រាប់អីទេ។

កៈ ហើយចុះជីដូនអីតារបស់អំមានឈ្មោះអីគេដែលអំ?

ខៈ នៃកពួកគាត់មានឈ្មោះថា តាលឹប យាយសិទ្ធ។

កៈ ឈ្មោះតាលឹប យាយសុទ្ធ អានិងខាងម្តាយឬក៏ខាងឪពុក?

ខៈ ខាងម្តាយ។

កៈ ខាងម្តាយ និងហើយចុះ?

ខៈ ខាងឪពុកអរ?

កៈ ចា។

ខ៖ ខាងឪពុកមានឈ្មោះថា តាកែ ហើយនិងយាយគង់។

ក៖ ចាហើយអ៊ំមានចាំនាមត្រកូលគាត់ទេអ៊ំ?

ខ៖ អត់ចាំទេ អរមើល ដូចជាតាលឹប និង សោមសុទ្ធ អរនួន លឹប។

ក៖ ចា។

ខ៖ អានិងខាងម្ដាយណា។

ក៖ ចា។

ខ៖ បើខាងឪពុកខ្ញុំអត់ចាំទេ។

ក៖ ចា

ក៖ ចាហើយពួកគាត់ស្លាប់អស់ហើយមែនទេអ៊ំ?

ខ៖ ចានិងហើយ ពួកគាត់ស្លាប់អស់ហើយ។

ក៖ ចាហើយពួកគាត់ស្លាប់មុនពពតឬក៏ក្រោយពពតដែលអ៊ំ?

ខ៖ ពួកគាត់ស្លាបើមុនពពតទៀត។

ក៖ ហើយអ៊ំកាលនិង។

ខ៖ ពួកគាត់ស្លាបើនិងចាស់ៗអស់ហើយនិង។

ក៖ ចាចុះអ៊ំកើតទាន់ពួកគាត់ទេអ៊ំ?

ខ៖ ទាន់ កើតទាន់។

ក៖ ចាហើយចុះអ៊ំនៅពីក្មេងនិងធ្លាប់ធ្វើអីគេខ្លះជាមួយយាយតារបស់អ៊ំណាអ៊ំ?

ខ៖ អរគ្រាន់តែលេងជាមួយគាត់គ្មានទៅធ្វើអីទេ។ អត់មានធ្វើអីផងនិងនៅតែផ្ទះនិង។

ក៖ ហើយអើខ្ញុំចង់សួរអ៊ំទៀតថា ពួកគាត់ធ្លាប់អើប្រាប់អ៊ំអំពីសាច់រឿងអីខ្លះសំរាប់អ៊ំទេអ៊ំ?

ខ៖ គាត់អត់ដែលប្រាប់រឿងអីទេ ទទេនិង។

កៈ ចឹងគាត់អត់ដែលនិយាយប្រវិត្តអីប្រាប់អំទេអីអំ?

ខៈ អត់ទេ អត់មិនដែលនិយាយអីទេ។

កៈ
ហើយអើខ្ញុំចង់សួរអំទៀតថាគ្រុមគ្រួសាររបស់អំដូចជាបងប្អូនរបស់អំដែលគាត់មានក្រុមគ្រួសារហើយនិង តើគាត់ទៅរស់នៅឯណាខ្លះដែលអំ?

ខៈ ទៅនៅប៉ោយប៉ែតម្នាក់។

កៈ ចាមាននៅឯណាទៀតអំ?

ខៈ នៅឯស្រុកឯនុះនិងពីរនាក់។

កៈ ស្រុកកំពងចាមនិងមែនអំ?

ខៈ និងហើយ អរបីរនាក់ បីរនាក់ដែលនៅនិង។

កៈ ចាហើយចុះអ្នកដែលគាត់ស្លាប់នោះ ហេតុអីបានគាត់ស្លាប់ចឹងអំ?

ខៈ គាត់ទៅអើនៅជំនាន់ពពតនិងទៅតាមគេទៅក៏បាត់រហូតទល់តែអាឡូវនិងទៅ។

កៈ ចាអំ។ ហើយអើចង់សួរអំថា តើអំមានសាច់ញាតិដែលរស់នៅប្រទេសក្រៅទេអំ?

ខៈ អត់មានទេ។

កៈ ហើយចង់សួរអំទៀតថាតើស្វាមីរបស់អំមានឈ្មោះអីដែល?

ខៈ ឈ្មោះ ក្ងង ខេង។

កៈ ក្ងង ខេង។

ខៈ និងហើយ។

កៈ ហើយអំបានរៀបអាពាហ៍ពីពាហ៍នៅពេលណាដែលអំ?

ខៈ ខ្ញុំរៀបការនៅពេលយួនចេញ។

កៈ ពេលយួនចេញ។

ខ៖ និងហើយ។

ក៖ ហើយរៀបការដោយចិត្តឯង ឬក៏ឪពុកម្តាយគាត់ជាអ្នករៀបចំអោយ?

ខ៖ ឪពុកម្តាយរៀបចំអោយ។

ក៖ ចាហើយអើអំរៀបការនៅឆ្នាំណាខែណាដែលអំ?

ខ៖ ហើយខ្ញុំមិនសូវចាំទេអាអើយ។

ក៖ ចាហើយខ្ញុំចង់សួរអំថាអំបង្កាប់ថ្លៃជំនួនពីអំប្រុសនិងប៉ុនន្មានដែល?

ខ៖ កាលនិងតិចតួចនិង។

ក៖ ចាហើយតើអំអាចប្រាប់ខ្ញុំពីពេលដំបូងដែលអំបានជួបអំប្រុសនិងណា មេចដែលអំ?

ខ៖ កាលនិងខ្ញុំស្គាល់តាបបងប្អូនប្រុសគាត់និង គាត់មកឃើញយើងចឹង
គាត់ក៏មកនិយាយជាមួយម្តាយយើងអីចឹងទៅ ហើយក៏គេនាំគ្នាគិតគូរទៅរៀបចំទៅ។

ក៖ ចាហើយអំ អំស្រលាញ់អំគាត់អត់?

ខ៖ ស្រលាញ់តែមិនសូចស្រលាញ់ណាម៉ានទេ។

ក៖ ហាហាហា តែតាមឪពុកម្តាយរៀបការអោយនុះអំនុះ?

ខ៖ ចានិងហើយ តាមឪពុកម្តាយការអោយ។

ក៖ ចាចុះខ្ញុំអាចសុំការអនុញ្ញាតពីអំសួរអំទាក់ទងជំនាន់ពពតវិញ
ចឹងអំបានឆ្លងកាត់សម័យនិងតើអំអើបានជួបអ្វីខ្លះនៅក្នុងជីវិតអំនៅពេលនិងណា
តើអំអាចរៀបរាប់?

ខ៖ កាលនិងខ្ញុំជួបនុះគឺ គេទំលាក់គ្រាប់បែបនាំគ្នារត់នៅតាមភូមិគេនិង
ហើយយើងបរទេះទៅចឹងពេលគេទំលាក់គ្រាប់បែកនិង
រត់ទៅហើយមួយភូមិនិងរត់ទៅទាំងអស់គ្នានិង រត់ទាំងអស់ ចូលរណ្តៅ
ហើយអោយតែឃើញកប៉ាល់ហោះមកដឹងតែនាំគ្នារត់ចូលរណ្តៅហើយ
និងហើយវាបាញ់វាបោះ។

ក៖ ហើយកាលនិងអំមានអាយុប៉ុន្មាន?

ខ៖ ខ្ញុំអាយុដប់ប្រាំឆ្នាំ។

ក៖ ចាហើយនៅពេលនិងមេចទៀត អ៊ំចងចាំអីខ្លះអ៊ំអាចនិយាយ?

ខ៖ តែប៉ុននិង។

ក៖ ចាហើយកាលពេលអ៊ំនៅសម័យពពតនិងអ៊ំរស់នៅជុំឪពុកម្ដាយអ៊ំ ឬក៏បែកគ្នា?

ខ៖ ខ្ញុំរស់នៅជាមួយម្ដាយ ជួបជុំគ្នាទាំងអស់គ្នានិង កាលនិងខ្ញុំមិនទាន់មានគ្រួសារទេ។

ក៖ ចាហើយកាលជំនាន់និងអ៊ំដូចជាត្រូវទៅសែងដី សែងអីដែលមែនទេអ៊ំ?

ខ៖ និងហើយរែកដីរែកអី នៅជំនាន់អាពពតនិងគេបញ្ជូនអោយទៅរែកដីរែកអីនិងដែល តែនៅឆ្ងាយៗណាខ្ញុំគេអោយធ្វើកង់ចល័ត។

ក៖ ចានិយាយពីកង់ចល័តនិងគេធ្វើអីវិញអ៊ំ?

ខ៖ កង់ចល័តនិងគេចុះទៅនៅតាមភូមិ តាមឃុំគេនិងណា បើគេនៅភូមិនេះគេហៅទៅស្ទូង យើងទៅស្ទូងទៅ គេហៅទៅរែកដីក៏ទៅរែកដីទៅ ចា។

ក៖ កាលអ៊ំអើនៅក្នុងជំនាន់ពពតនិងអ៊ំនៅខេត្តណា ស្រុកណាដែលអ៊ំ?

ខ៖ ខ្ញុំនៅនិងខេត្តនិង ខេត្តស្រុកកំពង់ចាមស្រុកឪពុកខ្ញុំនិង។

ក៖ ចាហើយអ៊ំអត់មានផ្លាស់ទីលំនៅទៅណាទៀតទេ?

ខ៖ អត់ទេភូមិខ្ញុំនៅតែនិងម៉ង់។

ក៖ ចាចឹងទើបតែពេលអ៊ំរៀបការហើយបានមកនៅភ្នំពេញ?

ខ៖ ចា។

ក៖ ហើយអ៊ំមកនៅភ្នំពេញនេះប៉ុនន្មានឆ្នាំហើយ?

ខ៖ អើជាប់មួយម្ភៃឆ្នាំជាងហើយ។

ក៖ ចាហើយអ៊ំមានកូមចៅប៉ុន្មាននាក់ដែលអ៊ំ?

ខ៖ កូនចៅប្រាំនាក់។

កះ ចាចឹងពួកគាត់ការអស់ហើយមែនទេអ៊ំ?

ខះ រៀបការអស់ហើយ នេះពៅគេហើយនិង។

កះ ចាហើយខ្ញុំចង់សួរអ៊ំទៀតថា តើអ៊ំចេះអាន និងចេះនិយាយ
និងសរសេរភាសាខ្មែរច្បាស់បានល្អដែលទេអ៊ំ?

ខះ ខ្ញុំអត់ចេះនិយាយអីទាំងអស់។

កះ ចុះអ៊ំអត់ដែលបានរៀនទេអ៊ំ?

ខះ អត់បានរៀនទេកាលនិងនៅជំនាន់អាពពតបានអីរៀន។

កះ អរចា។ ហើយចង់សួរថាអ៊ំចេះនិយាយភាសាអីផ្សេងទៀតទេអ៊ំ
ដូចជាភាសាថៃអីចេះទេ?

ខះ អត់សោះ អត់និងហើយ។

កះ ហើយអើខ្ញុំចង់សួរអ៊ំថាតើអ៊ំមានមិត្តភក្តិស្និទ្ធស្នាលដែលធំធាត់ឡើងជាមួយគ្នាទេអ៊ំ?

ខះ អត់ដែលមានទេ មិនដែលមានមិត្តភក្តិអីផង។

កះ ចាខ្ញុំចង់សួរអ៊ំទៀតថាអ៊ំធ្លាប់ធ្វើការនៅវាលស្រែដែលឬទេអ៊ំ?

ខះ ចាសួរថាមេច?

កះ អ៊ំធ្លាប់ធ្វើការនៅវាលស្រែទេ?

ខះ មានចេះតែស្ទូងដកនិង។

កះ ចាអ៊ំស្ទូងដកមេចខ្លះ ធ្វើខ្លួនឯងឬក៏ធ្វើអោយគេដែលអ៊ំ?

ខះ ធ្វើខ្លួនឯង។

កះ ចាចឹងអ៊ំមានដីស្រែខ្លួនឯង?

ខះ និងហើយ ខ្ញុំមានដីស្រែខ្លួនឯង។

កះ ហើយអ៊ំធ្វើស្រែនៅក្នុងមួយឆ្នាំនិងប៉ុន្មានដងដែលអ៊ំ?

ខ៖ តែម្តងទេ។

ក៖ ម្តង ហើយអំព្យូរាស់ខ្លួនឯងឬក៏មេចដែលអំ?

ខ៖ ជួលគេ។

ក៖ ហើយស្ទង់ដកអី?

ខ៖ ស្ទង់ដកខ្លួនឯងខ្លះ ជួលគេនិងខ្លះទៅ។

ក៖ ចាហើយបន្ទាប់ពីធ្វើស្រែហើយអំធ្លាប់ធ្វើចំការទេអំ?

ខ៖ ធ្វើធ្លាប់ធ្វើ។

ក៖ ចំការអីគេដែលអំ?

ខ៖ ដាំសណ្តែកដាំពោត។

ក៖ ចាជាចំការរបស់អំដែល?

ខ៖ ចាតែជាចំកាជ្លេលគេទេ។

ក៖ ចាតើអំជួលគេអោយធ្វើអោយឬក៏មេចដែលអំ?

ខ៖ ខ្ញុំជួលគេអោយព្យូ តែយើងដាំខ្លួនយើងអីចឹងណា។

ក៖ ចាហើយក្នុងមួយឆ្នាំគេប្រមូលផលបានប៉ុន្មានដងដែលអំ?

ខ៖ អើបានតិចតួចដែលនិង សាំសែសិបម៉ឺន។

ក៖ ចាហើយអើខ្ញុំចង់សួរអំទៀតថាបន្ទាប់ពីនិងហើយ
តើអំមានធ្លាប់ប្រកមអាជីវកម្មរអីរកស៊ីអីដែលទេអំ?

ខ៖ អត់ទេនិងហើយមកនៅភ្នំពេញបានចេះរកស៊ី ដូចជាលក់ប្រហិតពងទាអីចឹងណា។

ក៖ ហើយនិងមានលក់កាហ្វេអីចឹងទៅអំ?

ខ៖ និងហើយមានលក់ការហ្វេអីចឹង។

ក៖ ចាហើយអំចេះអាជំនាញមុខរបស់និងមកពីណាដែលអំ?

ខ៖ ចា?

ក៖ អ៊ំចេះអាមុខរបស់លក់ការហ្វេនិងមកពីណាដែល?

ខ៖ រៀនចេះខ្លួនឯង ធ្វើលក់ខ្លួនឯង។

ក៖ ចាចុះអ៊ំលក់ប៉ុន្មានឆ្នាំហើយ?

ខ៖ លក់បានប៉ុន្មានទេមកដល់អាឡូវនិងលែងលក់ហើយបានកូនពីរហើយ
កាលពីមុននិងខ្ញុំទៅលក់នៅក្នុងសួននៅមុខវាំងអីនិងណា
និងហើយដស់យើងចាស់ៗអស់ទៅអោយកូនលក់ម្តង។
ដល់ពេលនេះទៅកូនខ្ញុំវាលែងលក់លែងអីទៅវាចូលធ្វើការរហូតមកដល់អាឡូវនិងក៏ឈប់
លែងលក់រហូតទៅ។

ក៖ ចាហើយអរគុណអ៊ំស្រី
ហើយខ្ញុំចង់សួអ៊ំស្រីទៀតថាតាំងពីក្មេងរហូតមកដល់ពេលនេះណា
តើជីវិតរបស់អ៊ំមានការផ្លាស់ប្តូរអីគេខ្លះដែលអ៊ំ?

ខ៖ អត់មានផ្លាស់ប្តូរអីផង។

ក៖ ចាដូចជាធ្លាប់ពីបាក អាឡូវមកស្រួលវិញអីចឹងណា?

ខ៖ អរអាឡូវនិងពីបាកដែលនិងណាលក់ដូរអីក៏វាមិនសូវដាច់អីនិងវាពិបាកណា
ពីបាករកណាអាឡូវនោះ មិនដូចកាលខ្ញុំនៅលក់ដូចពីមុនទេ។

ក៖ ហើយខ្ញុំចង់សួរអ៊ំទៀតថា តើអ៊ំមានម្ហូបណាខ្លះដែលអ៊ំចូលចិត្ត?

ខ៖ ម្ហូបនោះ ដូចថាម្ហូបមានសំល្លម្ជូរអី ស្លរកកូរ ស្លរប្រហើរ សំលឹក។

ក៖ ចឹងនិងសុទ្ធតែជាម្ហូបដែលអ៊ំចូលចិត្តនុះអ៊ំនុះ?

ខ៖ ចាអោយតែម្ហូបដែលមានបន្លែៗអីនិង។

ក៖ ហើយខ្ញុំចង់សួរអ៊ំទៀតថា
តើអ៊ំចូលចិត្តលេងល្បែងកំសាន្តអីខ្លះតាំងពីក្មេងរហូតមកដល់ពេលនេះណាស់
ដូចជាលេងបោះអង្គុញ ចោលឈូក លែងបិទពួនអីណា?

ខ៖ អត់ដែលទេអាឡូវ ខ្ញុំចាស់ៗអស់ហើយលែងចង់ហើយ ហាហាហា។

ក៖ ចាប៉ុនន្តែពីក្មេងអំធ្លាប់លែង?

ខ៖ និងហើយពីក្មែងធ្លាប់លែង លែងដេញចាប់។

ក៖ លែងជាមួយមិត្តភក្តិនៅជិតផ្ទះអីនិងទៅ?

ខ៖ ចាលែងដេញចាប់គ្នានិង។

ក៖ ហើយអើខ្ញុំចង់សួរអំទៀតថា តើអំចេះច្រៀងចំរៀងទេ?

ខ៖ អត់ចេះទេ។

ក៖ តែអំចូលចិត្តស្តាប់ចំរៀងអត់។

ខ៖ បើគេអោយស្តាប់ចូលចិត្តស្តាប់ បើអោយមើលរឿងមើល ហាហាហា។

ក៖ ហើយខ្ញុំចង់សួរអំថាដូចជាអំចូលចិត្តស្តាប់បទចំរៀងអីគេដែល? ដូចជាស៊ុន ស៊ីសាមុត រស់សិរីសោធាអីណាអំ?

ខ៖ និងហើយស្តាប់ចំរៀងគេនិង ក្មេងច្រៀងអាឡូវនិងអី។

ក៖ ចាហើយអំចូលចិត្តស្តាប់បទទុំទាវដែល?

ខ៖ ហាហាហា ទុំទាវស្តាប់។

ក៖ ចាហើយខ្ញុំចង់សួរអំទៀតថា
តើក្រុមគ្រួសាររបស់អំបងប្អូនកូនចៅអីមានអ្នកណាដែលចេះលែងឧបករណ៏ភ្លេងខ្មែរ ឬក៏ភ្លេងសម័យអីទេអំ?

ខ៖ អត់ អត់មានផង។

ក៖ ចាអត់ចេះទាំងអស់គ្នានុះអំ? ហើយចង់សួរទៀតថា
តើផ្ទះរបស់អំពីរមុននិងអាឡូវនិងណាមានលក្ខណះយ៉ាងមេចដែលតាំងពីអំនៅក្មេងរហូតមកដល់អាឡូវ?

ខ៖ អោយខ្ញុំបានផ្ទះនៅប៉ុននិងណាគ្រាន់ធូរធាតិច ប៉ុនន្តែអាឡូវនិងយ៉ាប់ហើយ។

កៈ ចាចឹងតើផ្ទះនេះផ្ទះអំខ្លួនឯងឬក៏ផ្ទះអំជួលគេដែលអំ?

ខៈ ផ្ទះខ្ញុំធ្វើខ្លួនឯង ប៉ុន្តែខ្ញុំជួលដីគេ។

កៈ ចាចឹងអំធ្លាប់សាងសង់ផ្ទះដែលចឹងការសាំថសង់ផ្ទះរបស់អំនិង
តើអំប្រើលើសំភារះអីគេខ្លះដែលអំ?

ខៈ គ្មានសំភារះអីទេ។

កៈ ចាដូចជាពូថៅ?

ខៈ និងហើយពូថៅ អាញ្ជូរ អាណារ តែប៉ុននិង។

កៈ ហើយនិងឈីនុះអំ?

ខៈ និងហើយឈីនិង។

កៈ ហើយឈីនិងអំទីញពីគេមកឬក៏រកខ្លួនឯងដែលអំ?

ខៈ ឈីនិងខ្ញុំទិញគេ។

កៈ ចាចឹងអើរបស់របរធ្វើផ្ទះនិងអំទិញគេទាំងអស់ ចុះអំមានជួលជាងគេធ្វើទេអំ?

ខៈ អត់ទេមានជាងខ្លួនឯង តានិងគាត់ធ្វើជាមួយកូន។

កៈ អើចាចឹងមានន័យថាផ្ទះនិងអត់ជួលជាងទេ
តែកូនរបស់អំហើយនិងអំប្រុសទេដែលធ្វើផ្ទះនិង?

ខៈ ចា។

កៈ ចាហើយខ្ញុំចង់សួអំទៀតថា
តើអ្នកណាគេដែលបង្រៀនអំប្រុសអោយចេះធ្វើផ្ទះនិងណា?

ខៈ អត់មានអ្នកណាបង្រៀនទេ គឺគាត់ចេះធ្វើខ្លួនឯងតែម្តង និងហើយ។

កៈ អត់ធ្លាប់ទៅរៀនអីនៅណាទេ?

ខៈ អត់ទេអត់ដែលបានទៅរៀនឯងណាទេ
តែគាត់ចេះធ្វើខ្លួនឯងម៉ងទាំងពីរអ្នកឪពុកកូននិងឯង។

កៈ ចាហើយអើខ្ញុំចង់សួរអ៊ំទៀតថា តើឪពុកម្ដាយរបស់អ៊ំនិងណា
គាត់ធ្លាប់មានបន្សល់ទុកនូវទេពកោសល្យអ្វីមួយដូចជាជំនាញក្នុងស្ទូរវិញស្លឹក អីអោយអ៊ំធ្វើទេអ៊ំ
។

ខៈ អត់ អត់មានផងនិង។

កៈ ចា។

ខៈ ចាអត់មានទេ។

កៈ ចាហើយចុះខ្ញុំចង់សួរអ៊ំមួយទៀតថា
តើអ៊ំអាចប្រាប់ខ្ញុំពីពេលណាខ្លះដែលអ៊ំលំបាកខ្លាំងជាងគេបំផុតនៅក្នុងជីវិតរបស់អ៊ំណា?

ខៈ អើយពិបាកណា គ្មានលុយគ្មានកាក់អីចឹងណាអត់រកស៊ីអីនៅតែផ្ទះ
កូនរកស៊ីចិញ្ចឹមចឹង។

កៈ
ចុះអ៊ំតាំងពីក្មេងមកពីមុនពេលដែលអ៊ំរៀបការណាតើអ៊ំមានធ្លាប់ជួបជីវិតមួយដែលកំសត់
ដែលពិបាកខ្លាំងទេអ៊ំ?

ខៈ មានជួបពិបាកដែលគឺខ្ញុំទៅដឹកបន្លែរដឹកអីខ្លួនឯងនៅឯស្រុកគេឯនុះ។

កៈ នៅស្រុកណាដែលអ៊ំ?

ខៈ អើនៅស្រុកព្រៃសណ្ដែក ដឹកកង់

កៈ ហើយយកទៅណាវិញអ៊ំ?

ខៈ ដឹកកង់យកទៅលក់នៅផ្សារជប់។

កៈ ចាហើយអ៊ំត្រូវរកស៊ីចិញ្ចឹមខ្លួនឯងចិញ្ចឹមប្អូនអីឬក៏មេចអ៊ំ?

ខៈ ខ្ញុំរកស៊ីចិញ្ចឹមម្ដាយបងប្អូន។

កៈ ចាហើយអ៊ំជិះកង់ទៅរហូត ទៅទិញបន្លែរទិញអីហើយជិះកង់មកវិញ។

ខៈ និងហើយ ជិះទៅទិញរួចជិះមកវិញ។

កៈ ចឹងឆ្ងាយនែអំ?

ខៈ ឆ្ងាយណាស់ជិតកោះសុទិន កោះប៉ែនណា។

កៈ
ចាហើយអើខ្ញុំចង់សួរអំទៀតថាតើអំឆ្លងកាត់អាការលំបាកនិងណាដោះយរបៀបណាដែលអំ?។

ខៈ វាលំបាកវេទនា មានភ្លៀងនៅតាមផ្លូវនិងវារអិល
ផ្លូវព្រៃកៅស៊ូនិងជិអកង់ឌុបបន្លែរមកចឹងណា ខ្ញុំលំបាកវេទនាណា។

កៈ ហើយនៅពេលដែលអំរៀបការហើយ
អើរៀបការជាមួយអំប្រុសនិងណាតើនៅតែពិបាកឬក៏?

ខៈ នៅតែពិបាកទល់តែមករស់នៅភ្នំពេញនិងបាន បានរៀងធូរជាបន្តិច។

កៈ ចាចឹងអាឡូវនិងធូរជាតិចហើយនុះអំ?

ខៈ ចាធូរជារ។

កៈ ហើយអើខ្ញុំចង់សួអំទៀតថា
តើអំមានអ្វីខ្លះដែលធ្វើអោយអំសប្បាយចិត្តនៅកនុងជីវិតរបស់អំណា?

ខៈ ហើយទល់តែមានលុយកាក់បានវាសប្បាយចិត្ត
បើអត់មានលុយកាក់ផងធើមេចនិងសប្បាយចិត្ត អត់សប្បាយចិត្តទេ។

កៈ ចាហើយចុះពេលការកូនការចៅអីអំសប្បាយចិត្តទេអំ?

ខៈ សប្បាយ។

កៈ ហើយចុះពេលអើកូនរបស់អំការនិងតើអំត្រូវធ្វើអីគេខ្លះសំរាប់ពួកគាត់ណាអំ?
រៀបចំអីគេខ្លះមានទេអំ?

ខៈ រៀបចំនិងមានតែផ្លែឈើស្អីៗនិង
ឥវ៉ែតវ៉ាន់អីចឹងទិញមករៀបចំទៅការកូនការចៅចឹងណា។

កៈ ហើយភាគច្រើននៅពេលដែលអំការកូនចឹងទៅការនៅខាងប្រុសឬក៏ការនៅខាងស្រី?

ខ៖ ភាគច្រើការនៅខាងខ្ញុំ។

ក៖ កូនស្រីអំ អំមានកូនស្រីទាំងអស់មែនទេអំ?

ខ៖ កូនស្រីខ្ញុំនិង កូនស្រីនិងការនៅនិង។

ក៖ ចាហើយអំការកូនតែមួយនិងទេឬក៏មេចអំ?

ខ៖ ខ្ញុំការកូនពីរ ស្រីពីរទេខ្ញុំនោះ។

ក៖ ចាការនៅនេះទាំងអស់?

ខ៖ ការនៅនិងទាំងអស់។

ក៖ ចាហើយពេលកូនអំការអំសប្បាយចិត្តទេ?

ខ៖ សប្បាយ ហាហា។

ក៖ សប្បាយចិត្ត។

ខ៖ សប្បាយចិត្ត។

ក៖ ចាហើយខ្ញុំចង់សួអំមួយទៀតថា នៅពីក្មេងរហូតមកដល់អាឡូវនិងណា
តើអំធ្លាប់មានសង្ឃឹមថាអំចង់បានអី ចង់ធ្វើអីពេលដែលអំធំឡើងណា តើអំធ្លាប់មានទេ?

ខ៖ អត់ផង។

ក៖ ដូចជាអំចង់ធ្វើពេទ្យ ធ្វើគ្រូអីណាតើអំធ្លាប់មានក្តីស្រម៉ៃអីដែលទេអំ?

ខ៖ អត់មានស្រមោលស្រម៉ៃអីទេ អត់ផង។

ក៖ ចាហើយចឹងខ្ញុំចង់សួរអំមួយសំនួរទៀតថា ជាចុងក្រោយណា
បើសិនជាអំមានពាក្យពេជអីចង់ផ្តាំទៅកាន់កូនចៅជំនាន់ក្រោយរបស់អំ
តើអំនិងនិយាយអីខ្លះទៅកាន់ពួកគាត់?

ខ៖ ចង់អោយកូនប្រឹងរកស៊ីអីចឹងណា ពេលវាដអត់ពីខ្ញុំទៅណា។

ក៖ ចាអំ។

ខ៖ និងហើយអោយវាប្រឹងរកស៊ីទៅខិតខំទៅចិញ្ចឹមកូន ចិញ្ចឹមចៅ។

កៈ ចាហើយនិងចង់អោយចៅៗខំរៀនណាអ៊ំ?

ខៈ និងហើយអោយចៅៗខំប្រឹងរៀនសូត្រអីចឹងទៅ។

កៈ ចាអោយដើរផ្លូវល្អចឹងទៅអ៊ំ?

ខៈ និងហើយ អោយដើរផ្លូវល្អ កុំអោយសេបគុកគ្រឿងញៀន គ្រឿងអី។

កៈ ចាអរគុណអ៊ំ ចឹងជាចុងក្រោយអ៊ំមានពាក្យពេជអីជូនពរកូនចៅអ៊ំណា
អោយគាចត់រកស៊ីមានបានឬក៏អីណាអ៊ំមានទេ?

ខៈ អោយកូនចៅរកស៊ីមានបានចឹងទៅ។

កៈ អោយពួកគាត់មានភាពរិកចំរៀន?

ខៈ ចានិងហើយ។

កៈ ចាចឹងខ្ញុំអរគុណច្រើនអ៊ំ
ហើយសំរាប់ការសំភាស៍មួយនិងខ្ញុំអាចសុំការអនុញ្ញាតពីអ៊ំដើម្បីដាក់នៅក្នុងប្រពន្ធវើបសាយរបស់សាលា BYU បានដែលទេអ៊ំ?

ខៈ បានចាបាន។

កៈ ចាចឹងជាចុងក្រោយខ្ញុំអរគុណអ៊ំដែលបានជួបអោយខ្ញុំពិភាក្សាជាមួយអ៊ំ
ហើយនិងធ្វើការសំភាស៍ដស់អ៊ំ ចឹងខ្ញុំសុំអរគុណច្រើនអ៊ំ។